ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ១១១០ សរជណ

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៨

**សូមគោរពជូន**

**ឯកឧត្តមកិត្តិបណ្ឌិត រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**កម្មវត្ថុ** : ស្តីពីការចាត់បញ្ជូនមន្ត្រីរាជការក្រុបខ័ណ្ឌក្រសួងមហាផ្ទៃសរុបចំនួន៨៧រូប (ស្រី១៧រូប) ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៨ នៅសាលាភូមិន្ទរដ្ឋបាល ចាប់ពីថ្ងៃទី០១ **ខែកក្កដា ឆ្នាំ**២០១៨ រហូតបញ្ចប់វគ្គបណ្តុះបណ្តាល។

**យោង** :
- លិខិតលេខ ២៦៨ ស.ភ.រ ចុះថ្ងៃពុធ ៨កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាភូមិន្ទរដ្ឋបាល
- សេចក្តីសម្រេចលេខ ២៧០ ស.ភ.រ ចុះថ្ងៃពុធ ៨កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ របស់សាលាភូមិន្ទរដ្ឋបាល
- លិខិតលេខ ៣៨២ លស ចុះថ្ងៃអង្គារ ១២រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ៥២៤ សជណ ចុះថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ៣៣៤០ មស.សករ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមកិត្តិបណ្ឌិត** ថា ក្រសួងមហាផ្ទៃសូមចាត់បញ្ជូនមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃសរុបចំនួន៨៦រូប (ស្រី**១៧**រូប) ដែលត្រូវបានទទួលស្គាល់ជាកម្មសិក្សាការីវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ កម្មសិក្សាការីវគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល កម្មសិក្សាការីវគ្គវិក្រឹត្យការមន្ត្រីមធ្យម និងកម្មសិក្សាការីវគ្គវិក្រឹត្យការមន្ត្រីក្រមការ ឱ្យចូលរួមវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៨ នៅសាលាភូមិន្ទរដ្ឋបាល ចាប់ពីថ្ងៃទី០១ **ខែកក្កដា ឆ្នាំ**២០១៨ រហូតបញ្ចប់វគ្គបណ្តុះបណ្តាល ដែលរួមមាន៖

I. **វគ្គបណ្តុះបណ្តាលបន្តមន្ត្រីជាន់ខ្ពស់**

| | |
|---|---|
| ១.វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ | ចំនួន១២រូប (ស្រី ០០រូប) |
| ២.វគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល | ចំនួន១៨រូប (ស្រី ០១រូប) |

II. **វគ្គបណ្តុះបណ្តាលបន្តមន្ត្រីមធ្យម**

| | |
|---|---|
| ១.វគ្គវិក្រឹត្យការមន្ត្រីមធ្យម | ចំនួន១៧រូប (ស្រី ០៧រូប) |
| ២.វគ្គវិក្រឹត្យការមន្ត្រីក្រមការ | ចំនួន៣៩រូប (ស្រី ០៩រូប) |

ដោយឡែក លោក **នី បុទិត្យ** មន្ត្រីនៃទីចាត់ការអន្តរវិស័យ សាលាខេត្តកែប ដែលមិនបានចូលរៀនវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ក្នុងឆ្នាំ២០១៧ ត្រូវបានសាលាភូមិន្ទរដ្ឋបាលអនុញ្ញាតឱ្យចូលរៀនវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ក្នុងឆ្នាំ២០១៨វិញ។

ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

សូមជូនភ្ជាប់មកជាមួយនូវលិខិតបង្គាប់ការ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមកិត្តិបណ្ឌិត** មេត្តាជ្រាបតាមការគួរ។

សូម **ឯកឧត្តមកិត្តិបណ្ឌិត** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ៕

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ស៊ុត_សេដ្ឋា**

**<u>ចម្លងជូន៖</u>**

- សាលាភូមិន្ទរដ្ឋបាល
- នាយកដ្ឋានបុគ្គលិក

  **"ដើម្បីជូនជ្រាប"**

- ឯកសារ-កាលប្បវត្តិ

**<u>សូមទំនាក់ទំនង</u>**

- លោក ងួន គឹមសេង
- ទូរស័ព្ទលេខ : ០១១ ៣២២ ២២៧